# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៤៧ សសរ

## សេចក្តីសម្រេច

### ស្តីពី

### ការតែងតាំងសមាជិកភាពថ្មី ជំនួសសមាជិកភាពចាស់ នៃសមាជិក សមាជិកា គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤ដែលប្រកាសអោយប្រើច្បាប់ស្តី ការរៀបចំ និង ការប្រព្រឹត្ត ទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែល ប្រកាស ប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើត គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ ១១ សសរ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការតែងតាំង សមាសភាពសមាជិក សមាជិកា នៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

### សម្រេច

**ប្រការ១:** ត្រូវបានតែងតាំងជាសមាជិកភាពថ្មីជំនួសសមាជិកភាពចាស់នៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃ ស្ត្រី និងគ្រួសារខ្មែរ ក្នុងស្ថាប័នរដ្ឋមួយចំនួន ក្នុងប្រការ ១នៃសេចក្តីសម្រេច លេខ ១១ សសរ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៧ ស្តីពីការតែងតាំង សមាសភាពសមាជិក សមាជិកា នៃគណៈកម្មាធិការជាតិលើក កម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដូចខាងក្រោម:

១-លោកជំទាវ **ស៊ី ដេហ៊ីន** រដ្ឋលេខាធិការក្រសួងកិច្ចការនារី ជាអនុប្រធានអចិន្ត្រៃយ៍ ជំនួស លោកជំទាវ **យូ អយ** បច្ចុប្បន្នជាឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសថៃឡង់

២-លោកជំទាវ **ម៉ិញ កុសនី** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាអនុប្រធាន ជំនួសឯកឧត្តម **ហ៊ឹម ឆែម** បច្ចុប្បន្ន រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

៣-លោកជំទាវ **ឌុំ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន ជំនួសឯកឧត្តម **ខេព ឆុន្នី** បច្ចុប្បន្ន រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី

៤-លោកជំទាវ **សុខ ចិន្តាយ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិកាជំនួសលោកជំទាវ **ឈឹម ណាឡា**

៥-ឯកឧត្តម **ឈាង ឆាត់** អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសមាជិក ជំនួសឯកឧត្តម **ប៉ុល ម៉េងហួរ** បច្ចុប្បន្នអនុរដ្ឋលេខាធិការក្រសួងទេសចរណ៍

៦-លោកជំទាវ **ឆន់ សារ៉ុម** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិកា ជំនួស ឯកឧត្តម **ប៊ូយ ប៊ុណ្ណា**

៧-លោកជំទាវ **សម មុន្នីកា** អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ជាសមាជិកា ជំនួស លោកជំទាវ **កង បូរាណ**

៨-អ្នកអង្គម្ចាស់ **ឈឹម សូហ៊ីន** អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ជាសមាជិកា ជំនួស លោកជំទាវ **ស៊ី ដេហ៊ីន** បច្ចុប្បន្នរដ្ឋលេខាធិការក្រសួងកិច្ចការនារី

៩-ឯកឧត្តម **ហាក់ ប៊ុនធឿន** អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា ជាសមាជិក ជំនួសឯកឧត្តម **យិន លួត**

១០-ឯកឧត្តមឧត្តមសេនីយ៍ឯក **សូរ ផន** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ ជាសមាជិក ជំនួស ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** បច្ចុប្បន្នអគ្គស្នងការ នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ

**ប្រការ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ពាក់ពន្ធ័ និងសាមីខ្លួនដូចមានចែង ក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ